# ប្រវត្តិសាស្ត្រសង្ខេបរបស់ខ្មែរក្រហម

*ប្រែសម្រួលដោយ គ្រី ស៊ុយហៀង កែសម្រួលដោយ ញាណ សុជាតិ*

*ផ្នែកសំខាន់នៃអត្ថបទប្រវត្តិសាស្ត្រសង្ខេបខាងក្រោម គឺត្រូវបានផ្តល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជាចេញពីសៀវភៅរបស់លោក ឌី ខាំបូលី ដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» ។*

## *សេចក្តីសង្ខេប ៖*

*បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានស្គាល់ថាជាខ្មែរក្រហមបានឡើងកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ ហើយបន្តគ្រប់គ្រងប្រទេស រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ និរន្តរភាពរបស់បក្សត្រូវបានរក្សាជាសម្ងាត់រហូតដល់ឆ្នាំ១៩៧៧ ហើយគ្មាននរណាម្នាក់ក្រៅពីសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាស្គាល់ថាតើនរណាជាមេដឹកនាំនោះទេ (មេដឹកនាំទាំងនោះហៅខ្លួនឯងថា «អង្គការបដិវត្តន៍») ។*

*ខណៈពេលដែលខ្មែរក្រហមនៅគ្រប់គ្រងអំណាច ខ្មែរក្រហមបានបង្កើតគោលនយោបាយមួយដែលមិនអើពើពីជីវិតមនុស្ស ហើយក៏បានបង្កើតនូវការគាបសង្កត់ និងការសម្លាប់រង្គាលទ្រង់ទ្រាយធំទៀតផង ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសទាំងមូលឲ្យទៅជាមណ្ឌលឃុំឃាំងដ៏ធំមួយ ដែលបន្ទាប់មកបានក្លាយទៅជាផ្នូរកប់សាកសពប្រជាជនជិតពីរលាននាក់ ដែលក្នុងនោះរួមមានទាំងកម្មាភិបាលក៏ដូចជាមេដឹកនាំជាន់ខ្ពស់មួយចំនួនរបស់ខ្មែរក្រហមផ្ទាល់ផងដែរ ។*

## *ការកកើតនៃរបបខ្មែរក្រហម*

*ចលនាកុម្មុយនីស្តនៅកម្ពុជាកើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង ក្នុងអំឡុងទសវត្សរ៍៤០ ហើយត្រូវបានទទួលឥទ្ធិពលពីវៀតណាម ។ ដោយត្រូវបានជុតបន្ថែមដោយភ្លើងសង្គ្រាមឥណ្ឌូចិនលើកទីមួយនៅទសវត្សរ៍៥០ ហើយក្នុងអឡុងពេលម្ភៃឆ្នាំបន្ទាប់មកនោះ ចលនានេះបានចាក់ឫសចាក់គល់ដុះរាលដាលពេញផ្ទៃប្រទេស ។*

នៅក្នុងខែមិនា ឆ្នាំ១៩៧០ លោកសេនាប្រមុខ លន់ នល់ ដែលជាអ្នកនយោបាយកម្ពុជាម្នាក់ដែលធ្លាប់បម្រើជានាយករដ្ឋមន្ត្រីនោះ រួមជាមួយនឹងសហការីរបស់គាត់ដែលនិយមសហរដ្ឋអាមេរិកបានធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ចេញពីព្រះប្រមុខរដ្ឋដោយជោគជ័យ ។ នៅពេលនោះ ខ្មែរក្រហមរឹតតែទទួលបានសមាជិកកាន់តែច្រើន ហើយត្រូវបានចាត់តាំងឲ្យក្លាយទៅជាអ្នកដើរតួដ៏សំខាន់បំផុតនៅក្នុងសង្គ្រាមស៊ីវិល ដោយសារតែសម្ព័ន្ធមិត្តដែលខ្មែរក្រហមមានជាមួយនឹងសម្ដេចសីហនុ ។ កងទ័ពរបស់ខ្មែរក្រហមត្រូវបានដឹកនាំដោយ ប៉ុល ពត ដែលត្រូវបានតែងតាំងឲ្យធ្វើជាលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាមេដឹកនាំនៅក្នុងឆ្នាំ១៩៦៣ ។ ប៉ុល ពត ដែលកើតនៅក្នុងប្រទេសកម្ពុជា ហើយមានឈ្មោះដើមហៅថា សាឡុត ស បានចំណាញពេលរស់នៅប្រទេសបារាំងមួយរយៈ ហើយបានក្លាយទៅជាសមាជិកម្នាក់នៅក្នុងបក្សកុម្មុយនីស្តបារាំង ។ នៅពេលត្រឡប់មកដល់ប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៣ ប៉ុល ពត បានចូលរួមចលនាកុម្មុយនីស្តសម្ងាត់មួយ ហើយចាប់ផ្ដើមបន្តការឡើងឋានៈរបស់ខ្លួនទៅជាបុគ្គលម្នាក់ក្នុងចំណោមអ្នកកាន់កាប់អំណាចផ្ដាច់ការដ៏អាក្រក់បំផុតនៅលើសកលលោក ។

ដោយមានជំនួយពីប្រទេសវៀតណាម ខ្មែរក្រហមចាប់ផ្ដើមវាយឈ្នះកងកម្លាំងរបស់ លន់ នល់ នៅគ្រប់សមរភូមិ ។ នៅចុងឆ្នាំ១៩៧២ វៀតណាមបានដកកងទ័ពចេញពីប្រទេសកម្ពុជា ហើយប្រគល់បន្ទុកសំខាន់ៗក្នុង ការធ្វើសង្គ្រាមនេះមកឲ្យបក្សកុម្មុយនីស្តកម្ពុជាវិញ ។

ចាប់ពីខែមករា រហូតដល់ខែសីហា ឆ្នាំ១៩៧៣ រដ្ឋាភិបាលរបស់របបសាធារណរដ្ឋខ្មែរដែលមានសហរដ្ឋអាមេរិកជាអ្នកផ្គត់ផ្គង់ខាងសព្វាវុធ បានទម្លាក់គ្រាប់បែកជាងកន្លះលានតោនមកលើប្រទេសកម្ពុជា ដែលធ្វើឲ្យប្រជាជនកម្ពុជាប្រហែលជាងបីសែននាក់ស្លាប់បាត់បង់ជីវិត ។ ប្រជាជនដែលខឹងសម្បារទៅនឹងការទម្លាក់គ្រាប់បែកនេះ ឬខឹងនឹងការបាត់បង់ជីវិតរបស់សាច់ញាតិបងប្អូនរបស់ខ្លួន បានចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម ។

នៅដើមឆ្នាំ១៩៧៣ ប្រហែលជាប៉ែតសិបប្រាំភាគរយនៃទឹកដីកម្ពុជា បានធ្លាក់ចូលក្នុងកណ្ដាប់ដៃរបស់ខ្មែរក្រហម ហើយកងទ័ពរបស់សេនាប្រមុខ លន់ នល់ ស្ទើរតែគ្មានលទ្ធភាពធ្វើការប្រយុទ្ធតទៅទៀត ។ ទោះបីជាយ៉ាងនេះក្ដី ដោយសារតែមានជំនួយពីសហរដ្ឋអាមេរិក កងទ័ពរបស់សេនាប្រមុខ លន់ នល់ អាចបន្តការប្រយុទ្ធជាមួយនឹងខ្មែរក្រហមបានរយៈពេលពីរឆ្នាំបន្តទៀត ។

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គឺជាពេលវេលានៃការបញ្ចប់ការអន្តរាគមន៍របស់បរទេសរយៈពេលប្រាំឆ្នាំ, ការទម្លាក់គ្រាប់បែក និងសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ។ នៅក្នុងកាលបរិច្ឆេទនេះផងដែរ ភ្នំពេញ ដែលជាទីក្រុងសំខាន់របស់ប្រទេសកម្ពុជា បានធ្លាក់ចូលទៅក្នុងកងកម្លាំងរបស់កុម្មុយនីស្ត ។

## ប្រទេសកម្ពុជានៅក្រោមរបបខ្មែរក្រហម

ប៉ុន្មានថ្ងៃបន្ទាប់ពីការឡើងកាន់កាប់អំណាចនៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងអស់ប្រហែលជាងពីរលាននាក់ និងទីប្រជុំជនផ្សេងៗទៀតឲ្យទៅរស់នៅទីជនបទដើម្បីធ្វើការងារស្រែចម្ការ ។ ប្រជាជនរាប់ពាន់នាក់បានបាត់បង់ជីវិតក្នុងពេលជម្លៀសនោះ ។

ខ្មែរក្រហមនៅពេលនោះ ក៏បានចាប់ផ្តើមអនុវត្តនូវកម្មវិធីកំណែទម្រង់របស់ខ្លួនតាមលទ្ធិម៉ៅ និងលទ្ធិម៉ាក្សលេនីនជ្រុលហួសហេតុនេះផងដែរ ។ ខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសង្គមជនបទមួយដែលមិនមានវណ្ណៈសង្គម ពោលគឺ គ្មានអ្នកមានគ្មានអ្នកក្រ ហើយគ្មានការកេងប្រវ័ញ្ច ។ ដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ ទីផ្សារសេរី ការអប់រំ ទ្រព្យសម្បត្តិឯកជន ម៉ូតសម្លៀកបំពាក់ ស៊ីវិល័យពីបរទេស ការអនុវត្តជំនឿសាសនា និងប្រពៃណីវប្បធម៌ខ្មែរ ។ សាលារៀន វត្តអារាម វិហារសាសនាអ៊ីស្លាម វិហារសាសនាគ្រិស្ត សាកលវិទ្យាល័យ ហាងលក់ទំនិញ និងអាគាររដ្ឋាភិបាលត្រូវបានបិទទ្វារ ឬក៏ប្រែក្លាយទៅជាគុក ក្រោលគោ ជំរំអប់រំកែប្រែ និងជង្រុកស្រូវ ។ សង្គមកម្ពុជានៅពេលនោះគឺគ្មានមធ្យោបាយដឹកជញ្ជូនជាឯកជនឬសាធារណៈ គ្មានទ្រព្យសម្បត្តិឯកជននិងគ្មានសិល្បៈកម្សាន្តណាដែលមិនមានលក្ខណៈបដិវត្តន៍នោះទេ ។ ការលម្ហែកម្សាន្តត្រូវបានអង្គការហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ ប្រជាជនទូទាំងប្រទេសរួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផងដែរនោះ ត្រូវតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅទាំងអស់ដែលជាប្រពៃណីបដិវត្តន៍របស់ខ្លួន ។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យមនុស្សគ្រប់រូបត្រូវបានដកហូតសិទ្ធិជាមូលដ្ឋានរបស់ខ្លួនទាំងអស់ ។ ប្រជាជនទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅសហករណ៍របស់ខ្លួននោះទេ ។ របបនេះមិនអនុញ្ញាតឲ្យប្រជាជនទាំងអស់ប្រមូលផ្តុំ និងពិភាក្សាគ្នាបានឡើយ ។ ប្រសិនបើមនុស្សបីនាក់ផ្តុំគ្នាហើយ

និយាយគ្នាលែងនោះ អ្នកទាំងនោះអាចត្រូវបានចោទប្រកាន់ថាជាខ្មាំងហើយអាចត្រូវបានចាប់ខ្លួនឬក៏សម្លាប់ចោលតែម្តង ។

ទំនាក់ទំនងក្នុងគ្រួសារ ក៏ត្រូវបានទទួលរងការរិះគន់យ៉ាងខ្លាំងក្លាផងដែរ ។ ប្រជាជនគ្រប់រូបត្រូវបានអង្គការហាមឃាត់មិនឲ្យបង្ហាញនូវសេចក្តីស្រឡាញ់ សេចក្តីសប្បាយរីករាយ ឬការអាណិតអាសូរសូម្បីតែបន្តិចបន្តួចក៏ដោយ ។ ខ្មែរក្រហមបានបង្គាប់បញ្ជាឲ្យប្រជាជនខ្មែរគ្រប់រូបជឿ ធ្វើតាម និងគោរពតាមអង្គការបដិវត្តន៍តែមួយគត់ដែលត្រូវបានអះអាងថាជា«ឪពុកម្តាយ»របស់ប្រជាជនគ្រប់រូប ។

ខ្មែរក្រហមបានអះអាងថា មានតែមនុស្សស្អាតស្អំប៉ុណ្ណោះដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការកសាងបដិវត្តន៍ ។ បន្ទាប់ពីដណ្តើមបានអំណាចភ្លាម ខ្មែរក្រហមបានធ្វើការចាប់ខ្លួន និងសម្លាប់ចោលនូវពលទាហាន មេបញ្ជាការកងទ័ព និងអ្នករដ្ឋការរបស់របបសាធារណៈរដ្ឋខ្មែរដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ ដែលខ្លួនចាត់ទុកថា មិនស្អាតស្អំអស់រាប់ពាន់នាក់ ។ ក្នុងរយៈពេលជាងបីឆ្នាំបន្ទាប់មកទៀត ក្រុមខ្មែរក្រហមបានធ្វើការកាប់សម្លាប់បញ្ញវន្ត អ្នករស់នៅទីក្រុង ជនជាតិភាគតិច ដូចជា ជនជាតិចាម វៀតណាម និងចិន អស់រាប់សែននាក់ ហើយខ្មែរក្រហមក៏បានសម្លាប់យោធា និងសមាជិកបក្សរបស់ខ្លួនអស់ជាច្រើននាក់ផងដែរដោយចោទថា ជាជនក្បត់ ។ អ្នកទាំងនោះភាគច្រើន គឺត្រូវបានយកទៅឃុំនៅក្នុងគុកដែលជាកន្លែងដែលពួកគេត្រូវបានឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។ គុកដែលសំខាន់បំផុតនៅប្រទេសកម្ពុជាត្រូវបានស្គាល់ថាជាមន្ទីរស-២១ ដែលមានអ្នកទោសប្រហែលជា ១៨,០០០នាក់ត្រូវបានជាប់នៅក្នុងគុកនេះ ខណៈពេលដែលគុកនេះដំណើរការ ហើយមានអ្នកទោសតែ១២នាក់ប៉ុណ្ណោះដែលអាចរស់រានមានជីវិតពីគុកនេះបាន ។

នៅក្រោមគម្រោង«ផែនការបួនឆ្នាំ»របស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជានៅទូទាំងប្រទេសត្រូវបានដាក់កម្រិតឲ្យធ្វើការបង្កបង្កើនផលឲ្យបានបីតោនក្នុងមួយហិកតា ។ នេះមានន័យថា ប្រជាជនត្រូវធ្វើការដាំដុះ និងប្រមូលកាត់ស្រូវដប់ពីរខែក្នុងមួយឆ្នាំ ។ នៅតាមតំបន់ភាគច្រើន ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការលើសពីដប់ពីរម៉ោងក្នុងមួយថ្ងៃ ដោយមិនមានពេលសម្រាកនិងម្ហូបអាហារគ្រប់គ្រាន់នោះទេ ។

## ការធ្លាក់ចុះនៃរបបខ្មែរក្រហម

រហូតមកដល់ចុងឆ្នាំ១៩៧៧ ការប៉ះទង្គិចជាមួយប្រទេសវៀតណាមបានផ្ទុះឡើង ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានខ្មែរក្រហមបញ្ជូនទៅសមរភូមិហើយត្រូវបានស្លាប់រាប់ពាន់នាក់ ។

នៅខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានធ្វើការវាយសម្រុកចូលប្រទេសកម្ពុជា ។ កងទ័ពវៀតណាមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ នៅពេលនោះ មេដឹកនាំខ្មែរក្រហមបានភៀសខ្លួនទៅភាគខាងលិចប្រទេស ហើយបានរៀបចំបង្កើតកងកម្លាំងរបស់ខ្លួនឡើងវិញនៅក្នុងទឹកដីថៃដោយមានជំនួយពីប្រទេសចិននិងថៃ ។ មហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតផ្តល់អាសនៈនៅអង្គការសហប្រជាជាតិឲ្យទៅក្រុមអ្នកតស៊ូប្រឆាំងនឹងកុម្មុយនីស្ត ដែលមានខ្មែរក្រហមនៅក្នុងនោះដែរ ។ ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថាជាតំណាងស្របច្បាប់តែមួយគត់របស់កម្ពុជា ។

នៅឆ្នាំ១៩៨២ ខ្មែរក្រហមបានចងសម្ព័ន្ធភាពជាមួយសម្តេចសីហនុម្តងទៀត ដែលត្រូវបាននិរទេសឲ្យទៅនៅប្រទេសចិនក្រោយពីសង្គ្រាមស៊ីវិលនៅកម្ពុជានិងមេដឹកនាំមិនមែនកុម្មុយនីស្ត សឺន សាន ដើម្បីបង្កើតជារដ្ឋាភិបាលចម្រុះត្រីភាគី ។ នៅភ្នំពេញឯណោះវិញ វៀតណាមបានជួយបង្កើតរដ្ឋាភិបាលថ្មីមួយគឺ “សាធារណរដ្ឋប្រជាមានិតកម្ពុជា” ដឹកនាំដោយសមមិត្ត ហេង សំរិន ។

ខ្មែរក្រហមបានបន្តនិរន្តរភាពរបស់ខ្លួនរហូតដល់ឆ្នាំ១៩៩៩ គឺនៅពេលដែលមេដឹកនាំខ្មែរក្រហមទាំងអស់ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ឬត្រូវចាប់ខ្លួន ឬទទួលមរណភាព ។ ប៉ុន្តែរបបខ្មែរក្រហមបានបន្សល់ទុកនូវភាពប្រេះស្រាំក្នុងសង្គមជាតិរហូតដល់សព្វថ្ងៃនេះ ។

## ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន

ឧក្រិដ្ឋកម្មក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ គឺជាសោកនាដកម្មរបស់មនុស្សជាតិដ៏អាក្រក់បំផុតមួយក្នុងចំណោមសោកនាដកម្មទាំងឡាយនាសតវត្សរ៍ទី២០ ។ ប្រជាជនកម្ពុជាជិតពីរលាននាក់បានបាត់បង់ជីវិតដោយសារជម្ងឺ ដែលបណ្តាលមកពីការខ្វះខាតថ្នាំសង្កូវ និងសេវាសុខាភិបាល ការអត់អាហារ

ការសម្លាប់ ឬការធ្វើពលកម្មហួសកម្លាំង ។ មនុស្សរាប់ម៉ឺននាក់បានក្លាយទៅជាស្ត្រីមេម៉ាយ និងក្មេងកំព្រា ចំណែកឯអ្នកដែលធ្លាប់រស់នៅឆ្លងកាត់របបនេះវិញ បានទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារតែបទពិសោធន៍ដែលខ្លួនបានជួបប្រទះ ។ ប្រជាជនរាប់សែននាក់បានរត់ភៀសចេញពីប្រទេស ហើយក្លាយជាជនភៀសខ្លួន ។ គ្រាប់មីនជាច្រើនលានគ្រាប់ត្រូវបានបង្កប់ក្នុងដីដោយខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាល ដែលបណ្ដាលឲ្យមានមនុស្សរាប់ពាន់នាក់បានស្លាប់និងពិការតាំងពីទសវត្សរ៍៨០មក ។ ប្រជាជនកម្ពុជាមួយភាគធំជួបបញ្ហាផ្លូវចិត្ត ដោយសារតែក្រុមគ្រួសាររបស់ពួកគាត់ត្រូវបានបាត់បង់ដែលធ្វើឲ្យប៉ះទង្គិចដល់ផ្លូវចិត្តយ៉ាងខ្លាំង ។ កត្តាទាំងនេះ គឺជាមូលហេតុចម្បងមួយដែលបណ្ដាលឲ្យមានភាពក្រីក្រញាំញីក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ។